# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រម

១១-១០-២០០៤ -ព្រះរាជក្រម នស/រកម/១០០៤/០០៣ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុម ប្រឹក្សារាជសម្បត្តិ ២២៩៩

## II.ក្រសួងព្រះបរមរាជវាំង

### ក្រុមប្រឹក្សារាជសម្បត្តិ

១៤-១០-២០០៤ -សេចក្ដីសំរេច កសរ/សសរ/១០០៤/០០១ ស្ដីពីការជ្រើសរើសព្រះមហាក្សត្រនៃព្រះរាជា ណាចក្រកម្ពុជា ២៣០៦

## III.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

១៥-១០-២០០៤ -អនុក្រឹត្យលេខ ៦៧ អនក្រ.បកស្ដីពីការទទួលស្គាល់សាកលវិទ្យាល័យញូវតុនធីឡាយ ២៣០៨

១១-១០-២០០៤ -អនុក្រឹត្យលេខ ៥៣៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៣១១

១៥-១០-២០០៤ -អនុក្រឹត្យលេខ ៥៤០ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ២៣១២

១៥-១០-២០០៤ -អនុក្រឹត្យលេខ ៥៤១ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៣១៣

១៥-១០-២០០៤ -អនុក្រឹត្យលេខ ៥៤២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៣១៥

### ២.សេចក្ដីសំរេច

១១-១០-២០០៤ -សេចក្ដីសំរេចលេខ៦២សសរស្ដីពីការតែងតាំងសមាជិក-សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ២៣១៧

# ព្រះរាជក្រម

នស/រកម/១០០៤/០០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់បេយល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់លិខិតលេខ ២៥៦រស. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៤ របស់រដ្ឋសភា ស្តីពីសំណើសុំធ្វើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សារាជសម្បត្តិ

-បានទ្រង់យល់សេចក្តីសំរេចលេខ ០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសំរេចលេខ ០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់ស្តីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅ
# នៃក្រុមប្រឹក្សារាជសម្បត្តិ

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដើម្បីជ្រើសរើសព្រះមហាក្សត្រ និងធានានូវដំណើរការជាប្រក្រតីនៃរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ .-**

ការជ្រើសរើសព្រះមហាក្សត្រថ្មីជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ។

# ជំពូកទី ២

# ការរៀបចំ និង សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ

**មាត្រា ៣ .-**

អនុលោមតាមមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សមាសភាពក្រុមប្រឹក្សារាជសម្បត្តិ មានដូចខាងក្រោម :

| | |
|---|---|
| ១-ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២-ប្រធានរដ្ឋសភា | អនុប្រធានទី ១ |
| ៣-នាយករដ្ឋមន្ត្រី | អនុប្រធានទី ២ |
| ៤-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ | សមាជិក |
| ៥-សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ | សមាជិក |
| ៦-អនុប្រធានទី ១ ព្រឹទ្ធសភា | សមាជិក |
| ៧-អនុប្រធានទី ១ រដ្ឋសភា | សមាជិក |
| ៨-អនុប្រធានទី ២ ព្រឹទ្ធសភា | សមាជិក |
| ៩-អនុប្រធានទី ២ រដ្ឋសភា | សមាជិក |

មាត្រា ៤ .-

ប្រធានក្រុមប្រឹក្សារាជសម្បត្តិដឹកនាំអង្គប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ទទួលអាណត្តិ សេចក្តីសម្រេចនានា ដែលក្រុមប្រឹក្សារាជសម្បត្តិបានអនុម័ត ចាត់ចែងនិងរ៉ាប់រងការអនុវត្តន៍ច្បាប់ទាំងឡាយដែលទាក់ទងនឹងការគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រ ។

មាត្រា ៥ .-

ក្នុងករណីដែលប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមាន ឬ ពុំមានលទ្ធភាពបំពេញមុខងារបានដោយមានមូលហេតុច្បាស់លាស់ អនុប្រធានក្រុមប្រឹក្សារាជសម្បត្តិត្រូវទទួលភារកិច្ចចាត់ចែងការជំនួស ។

មាត្រា ៦ .-

ក្នុងករណីដែលប្រធាននិងអនុប្រធានក្រុមប្រឹក្សារាជសម្បត្តិអវត្តមាន ឬពុំមានលទ្ធភាពបំពេញមុខងារ បានដោយមានមូលហេតុច្បាស់លាស់ ក្រុមប្រឹក្សារាជសម្បត្តិនឹងត្រូវដឹកនាំដោយ :

-អនុប្រធានទី ១ ព្រឹទ្ធសភា ប្រធាន

-អនុប្រធានទី ១ រដ្ឋសភា អនុប្រធាន

មាត្រា ៧ .-

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងត្រូវទទួលបន្ទុករៀបចំទីកន្លែងប្រជុំ កន្លែងធ្វើការនិងធ្វើកំណត់ហេតុរបស់ក្រុមប្រឹក្សារាជសម្បត្តិ បន្ថែមលើភារកិច្ចបច្ចុប្បន្ន ។

កំណត់ហេតុនិងឯកសារទាំងអស់របស់ក្រុមប្រឹក្សារាជសម្បត្តិត្រូវរក្សាទុកក្នុងក្រសួងព្រះបរមរាជវាំង ហើយមិនត្រូវធ្វើឱ្យខូចខាតទៅក្រៅឡើយ ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ

**មាត្រា ៨ .–**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សារាជសម្បត្តិ ។ សមាជិកបីរូបយ៉ាងតិច អាចលើកសំណើសុំអោយកោះប្រជុំបាន ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិចាត់ទុកជាបានការ លុះត្រាតែមានសមាជិកប្រាំរូបយ៉ាងតិចឡើងទៅចូលរួមប្រជុំ ។ ការពិភាក្សានៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជសម្បត្តិត្រូវទុកជាការសម្ងាត់ ។

**មាត្រា ៩.–**

ការអនុម័តរបស់ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវយកតាមមតិភាគច្រើនដាច់ខាតគឺប្រាំសម្លេងឡើង តាមរយៈការបោះឆ្នោតដោយសម្ងាត់ ។

**មាត្រា ១០.–**

ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ ក្រោយពីពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ឬ ចូលនិវត្តន៍ ឬដាក់រាជ្យ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវជ្រើសរើសព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១១ .–**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរណាដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ អង្គឌួង ឬព្រះមហាក្សត្រ នរោត្តម ឬក៏ព្រះមហាក្សត្រ ស៊ីសុវត្ថិ ហើយដែលក្រុមប្រឹក្សារាជសម្បត្តិយល់ឃើញថាមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ក្នុងការបម្រើប្រជារាស្ត្រ ប្រជាជាតិនិងមាតុភូមិ ។

**មាត្រា ១២.-**

សមាជិកក្រុមប្រឹក្សារាជសម្បត្តិ ចាប់ពីបីរូបឡើងអាច ឧទ្ទេសនាមបេក្ខជនព្រះមហាក្សត្រថ្មីមួយអង្គបាន ។ សមាជិកក្រុមប្រឹក្សារាជសម្បត្តិមួយរូប មានសិទ្ធិឧទ្ទេសនាមបានតែបេក្ខជនមួយអង្គប៉ុណ្ណោះ ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជសម្បត្តិស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មី ត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ។

**មាត្រា ១៤.-**

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រថ្មី ទ្រង់ថ្លែងសច្ចាប្រណិធានដូចមានចែងក្នុងឧបសម្ព័ន្ធ ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សារាជ-សម្បត្តិចេញសេចក្តីសម្រេច ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ១៥.-**

ព្រះរាជពិធីអភិសេកព្រះមហាក្សត្រថ្មីតាមប្រពៃណីទំនៀមទម្លាប់នៃព្រះរាជវង្សានុវង្សខ្មែរអាចប្រព្រឹត្តទៅមុនពេលទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

ក្នុងករណីកាលៈទេសៈមិនអនុគ្រោះ ព្រះរាជពិធីអភិសេកនេះអាចនឹងលើកទៅធ្វើនៅក្រោយពេលប្រារព្ធព្រះរាជពិធីបុណ្យឈាបនកិច្ចថ្វាយព្រះសពព្រះមហាក្សត្របាន ។

## ជំពូកទី ៤

## បទប្បញ្ញត្តិពិសេស

**មាត្រា ១៦.-**

ព្រះមហាក្សត្រដែលទ្រង់បានយាងចូលនិវត្តន៍ ឬដាក់រាជ្យ និងព្រះមហេសី ត្រូវបានរក្សាបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញ និងមិនអាចនរណារំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គនៅគ្រងរាជសម្បត្តិ ។

## ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

ពរស.០៤១០.៣០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្តីជម្រាបជូនសម្តេចប្រមុខរដ្ឋស្តីទី

"ដើម្បីសុំហត្ថលេខា"

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ ៧៣៩ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រុមប្រឹក្សារាជសម្បត្តិ

ក្រសួងព្រះបរមរាជវាំង
គរស / សសរ / ១០០៤ / ០០១

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤

## សេចក្តីសម្រេច
## ស្តីពីការជ្រើសរើសព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

## ក្រុមប្រឹក្សារាជសម្បត្តិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៤/០០៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ២០០៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ
- បានឃើញកំណត់ហេតុរបស់គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើស ព្រះម-ហាក្សត្រថ្មី ចុះថ្ងៃព្រហស្បតិ៍ ១ កើត ខែអស្សុជ ឆ្នាំវក ឆស័ក ព.ស. ២៥៤៨ ត្រូវនឹងថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៤

## សម្រេច

ប្រការ ១.- ត្រូវបានជ្រើសរើស សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រះបរមនាម " ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី " ។

ប្រការ ២.- ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រារព្ធព្រះរាជពិធីសច្ចាប្រណិធាន មុនចូលគ្រងរាជសម្បត្តិ ។

ប្រការ ៣.- ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានក្រុមប្រឹក្សារាជសម្បត្តិ

ជា ស៊ីម

## ព្រះបរមនាម ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

****

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី ។

---

" អ្នកបម្រើមាតុភូមិ សាសនា ប្រជាជាតិ និងប្រជារាស្ត្រខ្មែរ ដោយស្មោះមឹភក្តិ និងភក្តីភាព ។ មហាក្សត្រ ដែលព្រះពុទ្ធ និង ព្រះឥន្ទ្រ លោកឧបត្ថម្ភ ។ អ្នកបង្រួបបង្រួមខេមរជនទាំងអស់ ។ អ្នកការពារឯករាជ្យ បូរណភាពទឹកដី និង សន្តិភាពនៃកម្ពុជា ព្រមទាំងសុភមង្គល សេរីភាព និង វិបុលភាព នៃប្រជារាស្ត្រខ្មែរ "

---

LE SERVITEUR FIDÈLE ET DÉVOUÉ DE LA PATRIE, DE LA RELIGION, DE LA NATION ET DU PEUPLE KHMERS, LE PROTÉGÉ DU BOUDDHA, D'INDRA. L'UNIFICATEUR DE TOUS LES KHMERS, LE DÉFENSEUR DE L'INDÉPENDANCE, DE L'INTÉGRITÉ TERRITORIALE, DE LA PAIX DU KAMPUCHEA ET DU BONHEUR, DE LA LIBERTÉ ET DE LA PROSPÉRITÉ DU PEUPLE KHMER.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៣ អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សាកលវិទ្យាល័យញូវតុនធីឡាយ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក.ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ជា ធីឡាយ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៤
- តាមសំណើររបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យញូវតុនធីឡាយ (Newton Thilay University) ហៅកាត់ជាភាសាខ្មែរ "ស.ញ.ធ" និងហៅកាត់ជាភាសាអង់គ្លេស

"N.T.U" ។ សាកលវិទ្យាល័យញូវតុនធីឡាយ មានទីតាំងស្ថិតនៅអាគារលេខ ១០០ វិថីចាស៊ីរ ផ្លូវលេខ ៥១ កែងនឹងផ្លូវលេខ ២០០ សង្កាត់ផ្សារថ្មី៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យញូវតុនធីឡាយ មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវ-ជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ សាកលវិទ្យាល័យញូវតុនធីឡាយ ធ្វើការបណ្តុះបណ្តាលថ្នាក់ :

- បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៧០ ក្រេឌីតជាមធ្យម
- បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១៤០ ក្រេឌីតជាមធ្យម និង ថ្នាក់អនុបណ្ឌិត

មាត្រា ៤ : ក្នុងដំណើរការចាប់ផ្តើមនេះ សាកលវិទ្យាល័យញូវតុនធីឡាយ មានមហាវិទ្យាល័យចំនួនបួន :

១. មហាវិទ្យាល័យភាសាបរទេស ដែលមានឯកទេស អប់រំភាសាអង់គ្លេស

២. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម ដែលមានឯកទេស នីតិសាស្ត្រ រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រ-នយោបាយ និង កិច្ចការសាធារណៈនិងអន្តរជាតិ

៣. មហាវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ដែលមានឯកទេស គ្រប់គ្រង គណនេយ្យ ទីផ្សារ គ្រប់គ្រងពា-ណិជ្ជកម្មអន្តរជាតិ ហិរញ្ញវត្ថុនិងធនាគារ គ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងទេសចរណ៍ គ្រប់គ្រង-សណ្ឋាគារនិងបដិសណ្ឋារកិច្ច គ្រប់គ្រងអភិវឌ្ឍន៍ និងអភិវឌ្ឍសេដ្ឋកិច្ច

៤. មហាវិទ្យាល័យព័ត៌មានវិទ្យា ដែលមានឯកទេស កម្មវិធីកុំព្យូទ័រ ជួសជុលនិងតំឡើងប្រព័ន្ធ ដាតា-បេសកុំព្យូទ័រ និង បច្ចេកវិទ្យាទូរគមនាគមន៍ ។

នៅអនាគត សាកលវិទ្យាល័យញូវតុនធីឡាយ អាចពង្រីក ឬប្តូរទីតាំង ឬបើកមហាវិទ្យាល័យ សាខា ឯកទេស និងប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យញូវតុនធីឡាយ ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ និង មានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយដែលមានភារកិច្ច អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : សាកលវិទ្យាល័យញូវតុនធីឡាយ ត្រូវអនុវត្តតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជ-រដ្ឋាភិបាលដែលបានកំណត់លើសកម្មភាព ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាល ។

មាត្រា ៧ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង របស់សាកលវិទ្យាល័យញូវតុនធីឡាយ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨ : សាកលវិទ្យាធិការនៃសាកលវិទ្យាល័យញូវតុនធីឡាយ មានភារកិច្ចទទួលខុសត្រូវ នៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ និងធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម។

មាត្រា ៩ : និស្សិតដែលរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យញូវតុនធីឡាយនិងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយសាកលវិទ្យាល័យញូវតុនធីឡាយ ហើយត្រូវបានទទួលស្គាល់ពីក្រសួង

អប់រំ យុវជននិងកីឡា ក្នុងករណី សាកលវិទ្យាល័យ បំពេញ និងអនុវត្តបាន តាមគោលការណ៍កំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ និងសាកលវិទ្យាល័យញូវតុនធីឡាយត្រូវទទួលបន្ទុកអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ ១០ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

សាលាក្រុងភ្នំពេញ

"ដើម្បីជ្រាបជាព័ត៌មាន"

ដូចមាត្រា ១០ "ដើម្បីអនុវត្ត"

ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៣៩ អនក្រ តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

### មាត្រា ១.-

តែងតាំងលោក **សុខ សាឌល** ជាអធិការនៃអគ្គាធិការដ្ឋាន ក្រសួងពាណិជ្ជកម្ម ។

### មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំ... ខែ តុលា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤០ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការផ្តល់គ្រឿងឥស្សរិយយស

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១.** –

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **និមមិន្ទ** ជូនឧត្តមសេនីយ៍ទោ **សែម សុវណ្ណនី** មេបញ្ជាការរងបញ្ជាការដ្ឋានវិស្វកម្ម នៃ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការបំពេញភារកិច្ចការងារបំរើជាតិមាតុភូមិ ។

**មាត្រា២.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

A115

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៦១ អនក្រ.តត...

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៙៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា ១.**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនមន្ត្រីយោធា និង អ្នកឯកទេស សហរដ្ឋអាមេរិក ចំនួន ០៦រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមចំណែក កសាងស្ពានបេតុងមួយកន្លែង និង សាលារៀន ០១ខ្នង នៅឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលជាអំណោយមនុស្សធម៌ របស់សហរដ្ឋអាមេរិក ចំពោះប្រជាជនកម្ពុជា ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយសហមេត្រី ថ្នាក់ សេនា :**

*1-Major Michael Weisz , J 45 Cambodia Desk Officer , U.S Pacific Command .*

*2-Major Craig Tippins , Chief , Office of Defense Cooperation .*

*3-Major Don Hicks , OIC , 412 th ENCOM FWD USA PRAC .*

*4--SFC Steven L . Walton , Contracting Officer , 45 th Corps Support Group ( FWD )*

ខ.**មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :**

*1-Mrs. Phuong Sophal , Budget and Training Officer ,ODC Cambodia .*

*2-Mr. Kay Yomeah , Assistant , ODC Cambodia .*

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B 98-99

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:......៥៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
៙៚
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រីទូត មន្ត្រីយោធា និង អ្នកឯកទេស សហរដ្ឋអាមេរិក ចំនួន ០៥រូប ដែលមានគុណបំណាច់ បានចូលរួមស្ថាបនា ស្ពានបេតុង និង សាលារៀន នៅឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលជាអំណោយមនុស្សធម៌ របស់សហរដ្ឋអាមេរិក ចំពោះប្រជាជនកម្ពុជា ដូចមានរាយនាមខាងក្រោម :-

*1-Ambassador Charles A. Ray , American Ambassador .*

*2-Colonel Steven Rundle , Defense Attaché .*

*3-Major Marc Harrelson , Chief , Office of Defense Cooperation .*

*4- Major Tuan Ton , J 52 Cambodia Desk Officer , U.S Pacific Command .*

*5-Mr. Ivan Keogh , QA/QC Engineer .*

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៧២...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការតែងតាំង សមាជិក_សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការ បង្កើត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់ ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## សំរេច

**ប្រការ ១.-**

ត្រូវបានតែងតាំងជាសមាជិកភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១.លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | ប្រធាន |
| ២.ឯកឧត្តម **គង់ ហ៊ុនធរិទ្ធ** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣.ឯកឧត្តម **ខួត សុច** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤.លោកជំទាវ **យូ អយ** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិកា |
| ៥.លោកជំទាវ **ឡាក់ ចន្ថា** | រដ្ឋលេខាធិការ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ៦.លោកជំទាវ **ស៊ិន ស៊ី** | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | សមាជិកា |

| | | |
|---|---|---|
| ៧.ឯកឧត្តម ម៉ក់ ទារិន់ | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. ឯកឧត្តម ង៉ិន ចន្ថា | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩. អ្នកអង្គម្ចាស់ស៊ីសុវត្ថិ ក្ខុឡាទេវី | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១០. លោកជំទាវ ម៉ុក ម៉ុណ្ណា | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិកា |
| ១១ .ព្រះអង្គម្ចាស់ក្សត្រិយ៍ នរោត្តម សេនានទី | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិកា |
| ១២. ឯកឧត្តម ថាច់ ផែន | រដ្ឋលេខាធិការ ក្រសួងពត៌មាន | សមាជិក |
| ១៣. ឯកឧត្តម អ៊ុ ឱហារ | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៤. ឯកឧត្តម ចាន់ មិន | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១៥. លោកជំទាវ អ៊ុ សុម៉ារីន | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |
| ១៦. ឯកឧត្តម ឈី អៀមឡាក់ | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. លោកស្រី ច័ន្ទ ហោរ៉ានវឌ្ឍី | អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិកា |

**ប្រការ២.-**

សមាជិក-សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នេះមានភារកិច្ច អនុវត្តការងារ ទៅតាមការតំរង់ទិស នៃព្រះរាជក្រឹត្យលេខ នស/រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៣.-**

សេចក្តីសំរេចលេខ ៧៣សសរ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីការតែងតាំងសមាជិក សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី-រដ្ឋលេខាធិការ -ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ឆ្នាំ ២០០៤

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ១ និងប្រការ៤
- ឯកសារ-កាលប្បវត្តិ